**MEDIA STATEMENT**

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

**មតិរបស់ឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស លោក ហ្សេដ រ៉ាអាដ អាល់ហ៊ូសេន (Zeid Ra'ad Al Hussein) ស្តីពីការចាប់ខ្លួនមេដឹកនាំគណបក្សប្រឆាំងកម្ពុជា លោក កឹម សុខា**

ទីក្រុងហ្សឺណែវ (៤ កញ្ញា ២០១៧) - ខ្ញុំមានកង្វល់យ៉ាងខ្លាំងចំពោះការចាប់ខ្លួនមេដឹកនាំគណបក្សប្រឆាំងកម្ពុជា គឺ លោក កឹម សុខា ដែលទំនងជាត្រូវបានអនុវត្តដោយមិនមានការគោរពចំពោះការធានាតាមនីតិវិធីត្រឹមត្រូវ រាប់ទាំងការមិនគោរពចំពោះអភ័យឯកសិទ្ធិសភារបស់លោក។

លោកត្រូវបានចោទប្រកាន់ពីបទក្បត់ជាតិ ដែលទោសនេះមានរយៈពេលជាប់ពន្ធនាគារចាប់ពី ១៥ ឆ្នាំ ទៅ ៣០ ឆ្នាំ ដោយផ្អែកលើខ្សែវីដេអូនៃសុន្ទរកថាមួយដែលលោកបានធ្វើនៅក្នុងឆ្នាំ២០១៣ និងដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈតាំងពីពេលនោះមក។ ខ្ញុំក៏មានការកង្វល់ផងដែរថាសេចក្តីថ្លែងការណ៍ជាសាធារណៈជាច្រើន ដោយលោកនាយករដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់មួយចំនួន អំពីពិរុទ្ធភាពដែលអាចមានរបស់ លោក សុខា បំពានលើការសន្មត់ជាមុនថាគ្មានទោស និងសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលគាត់មានសិទ្ធិទទួលបានក្រោមច្បាប់សិទ្ធិមនុស្សកម្ពុជា និងអន្តរជាតិ។

ការចាប់ខ្លួនរបស់លោក សុខា គឺជារឿងគួរអោយព្រួយបារម្ភថែមទៀត ព្រោះថាការចាប់ខ្លួននេះកើតមាននៅចំពេលមានវិធានការថ្មីៗជាច្រើនទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា។ វិធានការទាំងនេះបាននាំឲ្យមានការបិទអង្គការមិនមែនរដ្ឋាភិបាលបរទេសមួយ ហើយបានមានគោលដៅទៅលើក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយនានា ដែលរួមមានស្ថានីយ៍វិទ្យុជាច្រើន និងកាសែតឯករាជ្យដ៏ធំមួយដែលចុះផ្សាយជាភាសាអង់គ្លេស គឺ កាសែតឌឹខេមបូឌាដេលី ដែលពេលនេះត្រូវបានបង្ខំឲ្យបញ្ឈប់ការបោះពុម្ព បន្ទាប់ពីកាសែតនេះបានប្រតិបត្តិការអស់រយៈពេល ២៤ ឆ្នាំ មកហើយ។

ចប់

*សម្រាប់ព័ត៌មានបន្ថែម និងសំណើរព័ត៌មាន សូមទំនាក់ទំនង៖*
*លោក រ៉ូផើត ខូលវីល (Rupert Colville) - តាមរយៈទូរស័ព្ទលេខ +៤១ ២២ ៩១៧៩៧៦៧ ៧ ឬ តាមរយៈអ៊ីម៉ែល៖* rcolville@ohchr.org
*អ្នកស្រី លីហ្ស ស្រូសហ្សែលល៍ (Liz Throssell) តាមរយៈទូរស័ព្ទលេខ +៤១ ២២ ៩១៧ ៩៤៦៦ ឬតាមរយៈអ៊ីមែល៖* ethrossell@ohchr.org
*អ្នកស្រី រ៉ាវីណា សេមដាសានី (Ravina Shamdasani) តាមរយៈទូរស័ព្ទលេខ +៤១ ២២៩១៧៩១៦៩ ឬតាមរយៈអ៊ីមែល៖* rshamdasani@ohchr.org
**ថេក និង សែរ - ទ្វីធឺរ៖** @UNHumanRights **និងហ្វេសប៊ុក៖** unitednationshumanrights